# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៧២៨ MIH / ២០១៩

# ប្រកាស
## ស្តីពី
## ការពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ នៃសាធារណរដ្ឋកូរ៉េ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និង មាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ៤៥១MIH/2014 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- បានឃើញប្រកាសរួមលេខ ៧១៧សហវ-ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការងារចាំបាច់របស់ក្រសួង

# សម្រេច
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះ កំណត់ពីនីតិវិធីសម្រាប់ពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ ដោយអនុលោមតាមមាត្រា១៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

## ផ្នែកទី២
## ការសម្របសម្រួលពន្លឿនការផ្តល់ប្រកាសនីយបត្រតកក្កកម្ម

**ប្រការ២ ._**

ការពន្លឿនការផ្តល់ប្រកាសនីយបត្រតកក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ ត្រូវធ្វើនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣ ._**

អ្នកដាក់ពាក្យសុំ អាចស្នើសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតកក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មបាន ចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងពិនិត្យតក្កកម្ម ដែលបានធ្វើដោយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ។

**ប្រការ៤ ._**

ការស្នើសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានទទួល ចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវមានការប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ផ្អែកលើមូលដ្ឋានពាក្យសុំប្រកាសនីយបត្រតក្កកម្មកូរ៉េ ឬ

២-ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបម្រើជាមូលដ្ឋានសម្រាប់ប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដោយផ្អែកលើមូលដ្ឋានពាក្យសុំប្រកាសនីយបត្រតក្កកម្មកូរ៉េ រួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលពិនិត្យកម្រិតជាតិ ឬ

៣-ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលមានមូលដ្ឋានដូចគ្នាទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសម្រាប់ប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដោយផ្អែកលើមូលដ្ឋានពាក្យសុំអង្គភាពប្រកាសនីយបត្រតក្កកម្មកូរ៉េ រួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលពិនិត្យកម្រិតជាតិ។

**ប្រការ៥ ._**

ក្នុងការសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំត្រូវប្រើទម្រង់ពាក្យសុំដូចបានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងត្រូវបំពេញទិន្នន័យដូចខាងក្រោម៖

ក- ចំណងជើងតក្កកម្ម

ខ- កាលបរិច្ឆេទដាក់ពាក្យស្នើសុំ

គ- លេខសំណុំលិខិតស្នើសុំ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

ឃ-ឈ្មោះអ្នកដាក់ពាក្យសុំ

ង-សំណុំលិខិតស្នើសុំទាក់ទងនឹងអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ និង

ច-ឯកសារត្រូវផ្តល់ឱ្យមួយចំនួនទៀតដូចខាងក្រោម៖

- ច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មកូរ៉េ ដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ។
- បកប្រែជាភាសាអង់គ្លេសនូវសេចក្តីអះអាង និងលក្ខណៈបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។
- បកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខណៈបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេល ០១ (មួយ)ខែ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម។
- តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង។

**ប្រការ៦ ._**

ការស្នើសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មអាចទទួលយកបាន ចំពោះតែប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់នៅអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ ហើយមានលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវតែជាពាក្យស្នើសុំដែលមានកាលបរិច្ឆេទដំបូងបង្អស់ ដូចគ្នានឹងពាក្យស្នើសុំដែលបានដាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

២-ត្រូវតែមានទំនាក់ទំនងជាមួយនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ។

៣-ត្រូវតែមានសេចក្តីអះអាង ក្នុងពាក្យស្នើសុំដែលបានដាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយមានសេចក្តីអះអាងមួយ ឬច្រើនដូចទៅនឹងសេចក្តីអះអាង ដែលមាននៅក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មកូរ៉េ ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ។

**ប្រការ៧ ._**

ការស្នើសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ ពុំមានការបង់កម្រៃសេវាឡើយ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ៨ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ៩ .**_

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋាននីតិកម្ម គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រធានមន្ទីរឧស្សហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

***កិត្តិសេដ្ឋាបណ្ឌិត* ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

**ព្រះរាជាណាចក្រកម្ពុជា**
Kingdom of Cambodia
**ជាតិ សាសនា ព្រះមហាក្សត្រ**
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry and Handicraft
**អគ្គនាយកដ្ឋានឧស្សាហកម្ម**
General Department of Industry
**នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម**
Department of Industrial Property

# ពាក្យសុំប្រកាសនីយបត្រតក្កកម្មកម្ពុជា
# Patent Request Form (for PRP)

| | |
|---|---|
| **កម្មវត្ថុ៖** សំណើសុំពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្មកូរ៉េនៅកម្ពុជា តាមរយៈកម្មវិធីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម<br>Subject: Request for an accelerated patent decisions based on the PRP. | **សម្រាប់មន្ត្រីកាន់កាប់បញ្ជី**<br>For Registrar |
| | **កាលបរិច្ឆេទទទួល** :<br>Receiving Date |
| | **លេខរបស់សំណុំលិខិតស្នើសុំ** :<br>Application Number |
| | **កាលបរិច្ឆេទសុំចុះបញ្ជី** :<br>Filing Date |

លេខសំណុំលិខិតស្នើសុំ / Application number :..........................................................................

កាលបរិច្ឆេទសុំចុះបញ្ជី / Filing date :..........................................................................

ចំណងជើងនៃតក្កកម្ម / Title of invention :..........................................................................

..........................................................................................................................................

អ្នកដាក់ពាក្យសុំ / Applicant :..........................................................................

ពាក្យស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្មកូរ៉េលេខ:..........................................................

Corresponding patent number of Korea

ឈ្មោះភ្នាក់ងារ / Agent Name :...........................................................................................................

អាសយដ្ឋានភ្នាក់ងារ / Agent Address :...............................................................................................

ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម/ Attached Documents:

☐ ច្បាប់ចម្លងពាក្យសុំប្រកាសនីយបត្រតក្កកម្មកូរ៉េ ដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពប្រកាសនីយបត្រតក្កកម្មកូរ៉េ។
A copy of patent gazette in the corresponding KIPO patent application, and its certification by the KIPO

☐ សេចក្តីបកប្រែជាភាសាអង់គ្លេសនូវសេចក្តីអះអាង និងលក្ខណៈបច្ចេកទេស ដែលត្រូវបានពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។
Translation of Claims and Specification described in the patent gazette in English

☐ សេចក្តីបកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខណៈបច្ចេកទេស ដែលត្រូវបានពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។
Translation of Claims and Specification described in the patent gazette in Khmer (Translator must provide a self-declaration)

(**ចំណាំ**)អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេល០១(មួយ)ខែ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្ម យោងតាមប្រការ៥ នៃប្រកាស។

(**Note**) Applicant may submit the translation within one month of date on which the request of the PRP was filed refer to the rule 5 of Prakas.

☐ តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង / Claims correspondence table

ហត្ថលេខា / Signature

_______________________